# ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


០៣-១០-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១០០៩/៩៥៨ ស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមសញ្ញាតូបនីយកម្មដល់ លោក **ឆាយ មូយជុង** (CHAI MOOI CHONG) ជនជាតិម៉ាឡេស៊ី សញ្ជាតិម៉ាឡេស៊ី កើតនៅក្រុងប៉េណាង ប្រទេសម៉ាឡេស៊ី ៧៦៣២

០៨-១០-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១០០៩/៩៦៨ ស្តីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សប្ញទ្ធិ ចំពោះលោក ,លោកស្រី និងកញ្ញា ចំនួន ១៤ រូប ៧៦៣៣

០៨-១០-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១០០៩/៩៧០ ស្តីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ តាមលំដាប់ថ្នាក់ ចំពោះឯកឧត្តម,លោកជំទាវ និង លោកស្រី ចំនួន ០៤ រូប ៧៦៣៤

០៨-១០-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១០០៩/៩៧១ ស្តីពីការតែងតាំងលោកជំទាវ **ស៊ឿង រដ្ឋចារី** ជា អនុរដ្ឋលេខាធិការ និង ជាទីប្រឹក្សា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ មានឋានៈស្មើ រដ្ឋលេខាធិការ ៧៦៣៥

០៨-១០-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១០០៩/៩៧២ ស្តីពីការតែងតាំងទីប្រឹក្សាអមរាជបណ្ឌិតសភាកម្ពុជា ចំនួន ០២ រូប ៧៦៣៦

០៨-១០-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១០០៩/៩៧៣ ស្តីពីការតែងតាំងឯកឧត្តម **នូ ចាន់សុទ្ធី** ជាប្រធាន វិទ្យាស្ថានវប្បធម៌ និង វិចិត្រសិល្បៈ នៃរាជបណ្ឌិតសភាកម្ពុជា មានឋានៈស្មើ អគ្គនាយក ៧៦៣៧

០៩-១០-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១០០៩/៩៧៤ ស្តីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះឯកឧត្តម,លោកជំទាវ,លោក និង លោកស្រី ចំនួន១៦ រូប ៧៦៣៨

០៩-១០-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១០០៩/៩៧៥ ស្តីពីការប្រោសព្រះរាជទាន ចំពោះឯកឧត្តម **តែប ជុតិមា** នូវគ្រឿងឥស្សរិយយស ជាតូបការ ៧៦៣៩

០៩-១០-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១០០៩/៩៧៦ ស្តីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះឯកឧត្តម,ឧកញ៉ា និង អស់លោក ចំនួន ២៣ រូប ៧៦៤០

០៩-១០-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១០០៩/៩៧៧ ស្តីពីការផ្ទេរក្របខ័ណ្ឌលោកជំទាវ **ជូ ម៉ិនអេង** ពីឧត្តមមន្ត្រីថ្នាក់លេខ ៦ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងកិច្ចការនារី ទៅឧត្តមមន្ត្រីថ្នាក់លេខ ៦ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ៧៦៤១

០៩-១០-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១០០៩/៩៧៨ ស្តីពីការតែងតាំងឯកឧត្តម ខង់ សេងខង់ ជាទីប្រឹក្សាក្រសួងបរិស្ថាន មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន ៧៦៤២
០៩-១០-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១០០៩/៩៧៩ ស្តីពីការប្រោសព្រះរាជទាន ចំពោះព្រះតេជគុណ BILLY KIM នូវគ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេនា ៧៦៤៣
០៩-១០-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១០០៩/៩៨០ ស្តីពីការតែងតាំងឥស្សរជន ចំនួន ០២ រូបជាទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ រដ្ឋមន្ត្រី បន្ថែមលើមុខងារបច្ចុប្បន្ន ៧៦៤៤
០៩-១០-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១០០៩/៩៨១ ស្តីពីការតែងតាំងឯកឧត្តម ហ៊ុន សុធី ជាទីប្រឹក្សាប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានឋានៈស្មើ អនុរដ្ឋលេខាធិការ ៧៦៤៥
០៩-១០-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១០០៩/៩៨២ ស្តីពីការតែងតាំងជំនួយការឯកឧត្តម ឌិម យិនឡេង ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស មានឋានៈស្មើ អគ្គនាយក ចំនួន ០២ រូប ៧៦៤៦

## II-រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ

១៤-១០-២០០៩ -អនុក្រឹត្យលេខ ១៧៣ អនក្រ.បក ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ៧៦៤៧
១៤-១០-២០០៩ -អនុក្រឹត្យលេខ ១៧៤ អនក្រ.បក ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ ៧៦៥០
១៤-១០-២០០៩ -អនុក្រឹត្យលេខ ១៧៥ អនក្រ.បក ស្តីពីការបំបែកនាយកដ្ឋាន និង តម្លើងការិយាល័យ ទៅជានាយកដ្ឋានជំនាញ ចំណុះអគ្គនាយកដ្ឋានរដ្ឋបាលការពារ និង អភិរក្សធម្មជាតិ បំពេញបន្ថែមលើអនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះថ្ងៃទី ២៤ ខែមេសា ឆ្នាំ ២០០៨ ៧៦៥៥
១៤-១០-២០០៩ -អនុក្រឹត្យលេខ ១៧៦ អនក្រ.បក ស្តីពីការទទួលស្គាល់សាកលវិទ្យាល័យបញ្ញាជាតិ ៧៦៦០
១៤-១០-២០០៩ -អនុក្រឹត្យលេខ ១៧៧ អនក្រ.បក ស្តីពីការបង្កើតក្រុមប្រឹក្សានីតិកម្ម នៃ ក្រសួងមហាផ្ទៃ ៧៦៦៣
១៣-១០-២០០៩ -អនុក្រឹត្យលេខ ១៩៣២ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ *(ទើបបានទទួល)* ៧៦៦៧
១៣-១០-២០០៩ -អនុក្រឹត្យលេខ ១៩៣៤ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៧៦៦៩
១៣-១០-២០០៩ -អនុក្រឹត្យលេខ ១៩៣៥ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៧៦៧០
១៣-១០-២០០៩ -អនុក្រឹត្យលេខ ១៩៣៦ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិមន្ត្រីរាជការ ៧៦៧១
១៤-១០-២០០៩ -អនុក្រឹត្យលេខ ១៩៣៧ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៧៦៧៣
១៤-១០-២០០៩ -អនុក្រឹត្យលេខ ១៩៣៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៧៦៧៤

១៤-១០-២០០៩ -អនុក្រឹត្យលេខ ១៩៣៩ អនក្រ.តត ស្តីពីការជូនមេដាយសុវត្ថារា ៧៦៧៥

១៤-១០-២០០៩ -អនុក្រឹត្យលេខ ១៩៤០ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ៧៦៧៦


## ២-សេចក្តីសម្រេច


១៥-១០-២០០៩ -សេចក្តីសម្រេចលេខ ៦២ សសរ ស្តីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល ៧៦៧៧


## III-ការងារបណ្តាក្រសួង

## ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


០៩-១០-២០០៩ -ប្រកាសលេខ ៩០៦ សហវ.ប្រក ស្តីពីការបង្កើត និង ដាក់ឱ្យដំណើរការយន្តការភាពជាដៃគូ គយ-ផ្នែកឯកជន ៧៦៧៨

០៩-១០-២០០៩ -ប្រកាសលេខ ៩០៧ សហវ.ប្រក ស្តីពីការកំណត់កម្រៃឆ្លងកាត់ លើមុខទំនិញមួយចំនួនដែលស្ថិតក្រោមនីតិវិធីឆ្លងកាត់គយ ៧៦៨៤


## ២-អន្តរក្រសួង

## - ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## - ទីស្តីការរដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន


០៧-៩-២០០៩ -ប្រកាសអន្តរក្រសួងលេខ ៤១៤ ប្រក.សក-សហវ.ចមព ស្តីពីការកំណត់តម្លៃលេខចុះបញ្ជីរថយន្តធុនទេសចរណ៍ ៧៦៨៦


## ៣-ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម


២០-០១-២០០៩ -លិខិតបញ្ជាក់លេខ ០៣០៧ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ថប ឈ័យ អុិនវេសមេន (គ្រុប) (ខេមបូឌា) ៧៦៩២

២០-០១-២០០៩ -លិខិតបញ្ជាក់លេខ ០៣០៩ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ឌី.អិល.អិម.អុីមផត អិចផត ត្រេឌីង គ្រុប ៧៦៩៤

២០-០១-២០០៩ -លិខិតបញ្ជាក់លេខ ០៣១០ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ហង្ស ឌីង (ខេមបូឌា) ៧៦៩៦

២០-០១-២០០៩ -លិខិតបញ្ជាក់លេខ ០៣១៤ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ខេម យូ៉រ ផេត ឡូជីស្ទិក ៧៦៩៨

២០-០១-២០០៩ -លិខិតបញ្ជាក់លេខ ០៣១៥ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់សាខាក្រុមហ៊ុន ដាយ ដុង យឿង ខមមើសល យ៉ាញស្តុក ខមភេនី ៧៧០០

២០-០១-២០០៩ -លិខិតបញ្ជាក់លេខ ០៣១៦ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនិង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **យូ-ម៉ាត** ៧៧០១

២០-០១-២០០៩ -លិខិតបញ្ជាក់លេខ ០៣១៩ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនិង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ម៉ាន-លី រូរល ឌីវេឡុបមេន** ៧៧០៣

២០-០១-២០០៩ -លិខិតបញ្ជាក់លេខ ០៣២១ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនិង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ្វឹស-គ្លាស សឹលូសិន អិលធីឌី** ៧៧០៥

២០-០១-២០០៩ -លិខិតបញ្ជាក់លេខ ០៣២២ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនិង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **បេស ខ្មែរ អេនើជី** ៧៧០៧

២០-០១-២០០៩ -លិខិតបញ្ជាក់លេខ ០៣២៣ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេមបូឌាន ឆាយណា អ៊ិនធើណេសិនណល ម៉ាញ រីសសស៍ អិចផ្លរេសិន** ៧៧០៩

# ព្រះរាជក្រឹត្យ

នស/រកត/១០០៩/៩៥៧

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្សតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ឆាយ មួយជុង** (CHAI MOOI CHONG) ជនជាតិម៉ាឡេស៊ី សញ្ជាតិម៉ាឡេស៊ី កើតថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ១៩៥៩ នៅក្រុងប៉េណាង ប្រទេសម៉ាឡេស៊ី ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០៩*

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*៣រល. ០៩១០. ៩៧៥*

លេខៈ ៨២៧ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ១០ ឆ្នាំ ២០០៩
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**[illegible] ចិនគេន**

# ព្រះរាជក្រឹត្យ

នស/រកត/១០០៩/៩៦៨

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ

១- លោក យស សក្ដិដា
២- លោក សៅ វ៉ាន់ដេត
៣- លោកស្រី ពេជ្រ ចាន់ធី
៤- លោកស្រី អ៊ីម ស្រីមុំ
៥- លោក ប៊ូ សុវណ្ណារ៉េត
៦- កញ្ញា វ៉ាន់ សាម៉ាន
៧- លោកស្រី គីម សាមិត្ត
៨- កញ្ញា យុន សុឃីម
៩- កញ្ញា យុន សុឃឿន
១០- លោកស្រី ហេង ខួច
១១- លោកស្រី ពុធ ម៉ាលីយ
១២- កញ្ញា សៅ ចន្ទ្រា
១៣- លោកស្រី ស្រី សុគន្ធារី
១៤- លោក យ៉ាន ជន

ព្រះហស្ដលេខា និងព្រះរាជលញ្ឆករ
នរោត្ដម សីហមុនី

លេខៈ៩៧៧ ច.ល
[illegible] ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៩
អគ្គលេខាធិការរងនៃរាជរដ្ឋាភិបាល
[illegible] ជិនកេន

ពរល.០៩១០.៩៥៥

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០០៩

# ព្រះរាជក្រឹត្យ

នស/រកត/១០០៩/៩៧០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**

**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**

**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ទ្រង់ប្រោសព្រះរាជទាន**

**នូវ**

**ក. គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់មហាសេរីវឌ្ឍន៍**

១- ឯកឧត្តម **អ៊ុត ឈន**

២- លោកជំទាវ **តេ ជាលីន**

**ខ. គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់មហាសេនា**

១- លោកជំទាវ **ម៉ែន នារីសុផ្លី**

២- លោកស្រី **ឡាយ ហួង**

៣៧.០៩១០.៩៤៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០០៩*

លេខៈ ៩១១ ច.ល

[illegible] ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី១៥ ខែ ១០ ឆ្នាំ២០០៩

[illegible] អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible] ជិនកេង

# ព្រះរាជក្រឹត្យ

នស/រកត/១០០៩/៩៧២

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានតែងតាំងលោកជំទាវ **សឿង រដ្ឋចាវី** ជា **អនុរដ្ឋលេខាធិការ** និងជា **ទីប្រឹក្សាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី**ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្ត ឱ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខ:៧៦៣ ច.ល

៣រល.០៩២០.៩៧៩

**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ១៣ ឆ្នាំ២០០៩
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០០៩*

**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/១០០៩/៩៧២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិតសភាកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៥ ស្តីពីការកែសម្រួលមាត្រា៤ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ និង មាត្រា២០ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិតសភាកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១:** ត្រូវបានតែងតាំងទីប្រឹក្សាអមរាជបណ្ឌិតសភាកម្ពុជា ចំនួន០២រូប ដូចខាងក្រោម៖

១- លោកជំទាវ **តែ ទូចណាយ** មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

២- ឯកឧត្តម **មន់ សម្បត្តិ** មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

**មាត្រា២:** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣:** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០០៩*

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣រល. ០៩១០. ៩៧៩

លេខ: ៩៦២ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ២០០៩

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ស៊ុន ជិនគេន**

# ព្រះរាជក្រឹត្យ

នស/រកត/១០០៩/៩៧៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិតសភាកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៥ ស្តីពីការកែសម្រួលមាត្រា៤ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ និង មាត្រា២០ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិតសភាកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១:** ត្រូវបានតែងតាំង ឯកឧត្តម **នូ ចាន់សុភី** ជាប្រធានវិទ្យាស្ថានវប្បធម៌ និងវិចិត្រសិល្បៈ នៃរាជបណ្ឌិតសភាកម្ពុជា មានឋានៈស្មើ **អគ្គនាយក** ។

**មាត្រា២:** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣:** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល. ០៩១០. ៩៩០

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០០៩*

លេខៈ៩១០ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ១០ ឆ្នាំ២០០៩
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**[illegible] ជិនគេន**

ព្រះរាជក្រឹត្យ

នស/រកត/១០០៩/៩៧៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ **មហាសេរីវឌ្ឍន៍** ចំពោះ :

១-ឧត្តមសេនីយ៍ទោ ហួ ឫទ្ធី អត្តលេខ ០០៤៨៩២
២-លោកជំទាវ ឈួន ផល្លា
៣-លោក ឆាន់ សុភាព
៤-លោក ពេជ្រ ចាសនា

ខ-គ្រឿងឥស្សរិយយសសុវត្ថារា ថ្នាក់ **មហាសេរីវឌ្ឍន៍** ចំពោះ :

១-ឯកឧត្តម ឆាន់ សាផាន
២-ឧត្តមសេនីយ៍ទោ ឈួន ផាថរិទ្ធ អត្តលេខ ០០២៤៤៦
៣-ឯកឧត្តម ម៉ុង គឹមហេង
៤-លោក ឆាន់ សុវ្យផល

គ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ **មហាសេរីវឌ្ឍន៍** ចំពោះ :

១-ឧត្តមសេនីយ៍ត្រី សុខ សុចណ្ណនិត អត្តលេខ ០០៤៤៥៥
២-អ្នកស្រី ពេជ្រ សុខឡុត
៣-អ្នកស្រី ឆាន់ ចិរិយា
៤-អ្នកស្រី ឈន់ គូឡាបបុប្ផា

ឃ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ **មហាសេនា** ចំពោះ :

១-លោក ទេព ធន
២-អ្នកស្រី ចិន តា

ង-គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ **ធិបឌិន្ទ** ចំពោះ :

១-ឯកឧត្តម ជា ជាតិ
២-លោក ឡុង សុគន្ធ

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល.០៩៦០.៩៩១

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០០៩*

លេខ: ៧០៧ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ២០០៩
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

ស៊ុន ជិនគេង

# ព្រះរាជក្រឹត្យ

នស/រកត/១០០៩/៩៧៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ឯកឧត្តម កែប ជុតិមា

នូវ

គ្រឿងឥស្សរិយយស ជាតូបការ

៣រល.០៩១០.៩៩២

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៩

លេខ: ៩០៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ ១០ ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ស៊ុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/១០០៩/៩៧៨

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានតួមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

## ប្រោសព្រះរាជទាន

នូវ

ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ចំពោះ :-

| | | | | | | |
|---|---|---|---|---|---|---|
| ១ | ឧត្តមសេនីយ៍ទោ | ពៅ ស៊ីថា | ០០០៣២៧ | ២ | ឯកឧត្តម | ហេង រតនា |

ខ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ចំពោះ :-

| | | | | | |
|---|---|---|---|---|---|
| ១ | ឯកឧត្តម ឧកញ៉ា | គិត មេង | ២ | ឯកឧត្តម | គុក គឹមសាយ |

គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ចំពោះ :-

| | | | | | | |
|---|---|---|---|---|---|---|
| ១ | វរសេនីយ៍ឯក | កុយ សិរីវុឌ្ឍី | ០០២១០៨ | ២ | លោក | ព្រឹង បញ្ញារិទ្ធី |

ឃ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា ចំពោះ :-

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១ | វរសេនីយ៍ឯក | សំ សក | ០០៩៣៨២ | ៥ | វរសេនីយ៍ត្រី | ហុក ចិន្តា | ១៩៧៦៨៧ |
| ២ | វរសេនីយ៍ឯក | ហ៊ឹម សារ៉ុម | ០០៩៣៩០ | ៦ | វរសេនីយ៍ត្រី | សោម ណារ៉ង | ០១៩៩៨៧ |
| ៣ | វរសេនីយ៍ឯក | អ៊ុង ច័ន្ទថា | ០០៩៣៦៩ | ៧ | វរសេនីយ៍ត្រី | ខួន ស៊ីម | ០១៩៩៨៦ |
| ៤ | វរសេនីយ៍ត្រី | សែ ធី | ០១០៥០៣ | ៨ | វរសេនីយ៍ត្រី | ឈុច សារី | ០១៩៩៩០ |

ង-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ ចំពោះ :-

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១ | វរសេនីយ៍ទោ | វង្ស សារិន | ០០៩៣៦៩ | ៦ | វរសេនីយ៍ត្រី | កែ លន់ | ០២៩៩០២ |
| ២ | វរសេនីយ៍ទោ | អ៊ឹម យឿម | ០០៩២៩៧ | ៧ | វរសេនីយ៍ត្រី | អ៊ុង ម៉ុនរឿង | ០៤៤៩១១ |
| ៣ | វរសេនីយ៍ទោ | គា សុវណ្ណ | ០៤៧២៧២ | ៨ | អនុសេនីយ៍ឯក | ស្រី អេន | ០៤២០០៥ |
| ៤ | វរសេនីយ៍ទោ | អ៊ិត សុខុម | ០១៩០៦១ | ៩ | លោក | មាន តារ៉ុង |
| ៥ | វរសេនីយ៍ត្រី | រាជ្យ ធន | ០៣០២៣០ | | | | |

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

លេខ:៩៧០ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ២០០៩

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

[illegible]នគេន

តរល.០៩១០.៩៩៣

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៩*

# ព្រះរាជក្រឹត្យ

នស/រកត/១០០៩/៩៧៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មិនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានផ្ទេរក្របខ័ណ្ឌលោកជំទាវ **ជូ ម៉ិនរេង** ពីឧត្តមមន្ត្រីថ្នាក់លេខ៦ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងកិច្ចការនារី ទៅឧត្តមមន្ត្រីថ្នាក់លេខ៦ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៩*

៣រ៧.០៩១០.៩៩៤

លេខ:៩៦៩ ច.ល
...ចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០០៩
...ធិការរាជរដ្ឋាភិបាល
...ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/១០០៩/៩៧៤

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានតែងតាំងឯកឧត្តម **ទង់ ឆេងគង់** ជាទីប្រឹក្សាក្រសួងបរិស្ថាន មានឋានៈស្មើ **អគ្គនាយក** បន្ថែមលើមុខងារបច្ចុប្បន្ន។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រ.ល.០៩១០.៩៩៥

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៩*

លេខៈ ៩១៧ ច.ល
**ជម្រាបជូនដើម្បីចម្លងចែក**
រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៩
**អគ្គលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី**
**ហ៊ុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/១០០៩/៩៧៩

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

ចំពោះ

ព្រះតេជគុណ **BILLY KIM**

នូវ

គ្រឿងឥស្សរិយយស **សហមេត្រី** ថ្នាក់ **មហាសេនា**

៣រល.០៩២០.៩៩៦

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៩

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខៈ៩១៦ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០០៩
**អគ្គនាយកនៃអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល**

**ឃួន ជីនគេន**

# ព្រះរាជក្រឹត្យ

នស/រកត/១០០៩/៩៧០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឥស្សរជនចំនួន ០២ រូប ជាទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ រដ្ឋមន្ត្រី បន្ថែមលើមុខងារបច្ចុប្បន្ន ដូចមានរាយនាមខាងក្រោម ÷

- ឯកឧត្តម **ម៉ៅ ភិរុណ**
- ឯកឧត្តម **យឹម សាម៉ន**

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខៈ ៩១៥ ច.ល

៣៧.០៩១០.៩៩៧

**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ២០០៩
*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៩*
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

កេន

# ព្រះរាជក្រឹត្យ

នស/រកត/១០០៩/៩៧៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០៩/៦០៨ ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ត្រូវបានតែងតាំង ឯកឧត្តម **ហ៊ុន សុធី** ជាទីប្រឹក្សាប្រធាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧.ល.០៩១០.៩៩៧

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៩*

លេខ:៩៦៤ ច.ល
**ចម្លងចេញពីច្បាប់ដើម**
រាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០០៩
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ុន ចាន់ថុល**

# ព្រះរាជក្រឹត្យ

នស/រកត/១០០៩/៩៤៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** តែងតាំងជំនួយការឯកឧត្តម **ឱម យ៉ិនទៀង** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស មានឋានៈស្មើ **អគ្គនាយក** ដូចមានរាយនាមខាងក្រោម :

១- ឯកឧត្តម **យន់ ស៊ីណាត**

២- ឯកឧត្តម **បញ្ញា អ៊ិន** ។

**មាត្រា ២:** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខ: ៩១៧ ច.ល

៣៧.០៩២០.៩៩៩

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ២០០៩

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៩*

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ុន ជិនកេន**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:១៧៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## ស ម្រេ ច

មាត្រា១: - ត្រូវបានកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិចំនួនប្រាំមួយ(០៦)កន្លែង ជាតំបន់ប្រើប្រាស់ដោយចីរភាព សម្រាប់អភិវឌ្ឍន៍ និងវិនិយោគ ស្របតាមច្បាប់ស្តីពីតំបន់ការពារធម្មជាតិ រួមមាន:

ក- ត្រូវបានកំណត់តំបន់គ្រប់គ្រងក្នុងដែនជម្រកសត្វព្រៃស្នួល លើផ្ទៃដីទំហំ**៩.០៩៥ហិកតា ( ប្រាំពាន់ហាសិប ប្រាំបួនហិកតា)** ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ស្ថិតនៅក្នុងភូមិសាស្ត្រស្រុកស្នួល ខេត្តក្រចេះ សម្រាប់ផ្តល់ជូនក្រុមហ៊ុន **VIET - NAM KAMPUCHIA ECONOMY, TRADE AND INDUSTRY COMPANY LIMITED (VKETI) Co.,LTD)** ដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យកសិ-ឧស្សាហកម្ម ដាំដំណាំកៅស៊ូ ដូចមានក្នុងផែនទី និងនិយាមកា ដែលបានកំណត់ក្នុងឧបសម្ព័ន្ធ ១។

ខ- ត្រូវបានកំណត់តំបន់គ្រប់គ្រងក្នុងដែនជម្រកសត្វព្រៃស្នួល លើផ្ទៃដីទំហំ**ប្រាំបួនពាន់ ប្រាំបីរយ ហាសិបប្រាំហិកតា (៩.៨៥៥) ហិកតា** ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ស្ថិតនៅក្នុងភូមិសាស្ត្រស្រុកស្នួល ខេត្តក្រចេះ សម្រាប់ផ្តល់ជូនក្រុមហ៊ុន **ចំការកៅស៊ូ មេមត់ ខូ អិលធីឌី** ដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍លើដំណាំកៅស៊ូ ដាំដំណាំកសិ-ឧស្សាហកម្ម និងដំណាំកសិកម្ម ដូចមានក្នុងផែនទី និងនិយាមកា ដែលបានកំណត់ក្នុងឧបសម្ព័ន្ធ ២។

គ-ត្រូវបានកំណត់តំបន់គ្រប់គ្រងក្នុងដែនជម្រកសត្វព្រៃស្នួល លើផ្ទៃដីទំហំ**ប្រាំបួនពាន់ប្រាំពីររយប៉ែតសិប(៩.៧៨០) ហិកតា** ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ស្ថិតនៅក្នុងភូមិសាស្ត្រ ឃុំ ២ធ្នូ ស្រុកស្នួល ខេត្តក្រចេះ សម្រាប់ផ្តល់ជូនក្រុមហ៊ុន **ធីធីវ៉ាយ អភិវឌ្ឍន៍ ដំណាំកសិកម្ម ខូ អិលធីឌី** ដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យដំណាំកសិកម្ម ដំណាំកៅស៊ូ និងដំណាំកសិ-ឧស្សាហកម្ម ដូចមានក្នុងផែនទី និងនិយាមកា ដែលបានកំណត់ក្នុងឧបសម្ព័ន្ធ ៣។

ឃ-ត្រូវបានកំណត់តំបន់គ្រប់គ្រងក្នុងដែនជម្រកសត្វព្រៃស្នួល លើផ្ទៃដីទំហំ**ប្រាំមួយពាន់ ប្រាំរយ ម្ភៃប្រាំ(៦.៥២៥) ហិកតា** ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ស្ថិតនៅក្នុងភូមិសាស្ត្រ ស្រុកស្នួល ខេត្តក្រចេះ សម្រាប់ផ្តល់ជូនក្រុមហ៊ុន **សុវណ្ណ រាជសីហ៍** ដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យដំណាំកសិ-ឧស្សាហកម្ម ដាំដំណាំកៅស៊ូ ខ្លឹមច័ន្ទន៍ ដូចមានក្នុងផែនទី និងនិយាមកា ដែលបានកំណត់ក្នុងឧបសម្ព័ន្ធ ៤។

ង-ត្រូវបានកំណត់តំបន់គ្រប់គ្រងក្នុងដែនជម្រកសត្វព្រៃស្នួល លើផ្ទៃដីទំហំ**បួនពាន់ បួនរយ ហុកសិប ប្រាំបី(៤.៤៦៨) ហិកតា** ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ស្ថិតនៅក្នុងភូមិសាស្ត្រ ស្រុកស្នួល ខេត្តក្រចេះ សម្រាប់ផ្តល់ជូនក្រុមហ៊ុន **ត្រាញ ញៀម ហ៊ូហាន ដូវទី-ហ្វាតទ្រៀត ជាណាម-កម្ពុជា** ដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យដំណាំកសិ-ឧស្សាហកម្ម និងដំណាំកៅស៊ូ ខ្លឹមច័ន្ទន៍ ដូចមានក្នុងផែនទី និងនិយាមកា ដែលបានកំណត់ក្នុងឧបសម្ព័ន្ធ ៥។

ច-ត្រូវបានកំណត់តំបន់គ្រប់គ្រងក្នុងឧទ្យានជាតិព្រះសុរាម្រិត-កុសមៈ"គិរីរម្យ" លើផ្ទៃដីទំហំ **ប្រាំមួយរយ ប្រាំបួន (៦០៩) ហិកតា** ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ស្ថិតនៅតាមបណ្តោយបន្ទាត់ព្រំប្រទល់ឧទ្យានជាតិ ក្នុងភូមិសាស្ត្រខេត្តកំពង់ស្ពឺ សម្រាប់ផ្តល់ជូនក្រុមហ៊ុន **គិរីរម្យ អេក្កូធូរីស៊ឹម អ៊ិនវេសមេន** ដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យទេសចរណ៍ធម្មជាតិ ដូចមានក្នុងផែនទី និងនិយាមកា ដែលបានកំណត់ក្នុងឧបសម្ព័ន្ធ ៦។

**មាត្រា២: -**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៣ –**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គ្រប់ក្រសួង ស្ថាប័ន និងអភិបាលខេត្តពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៩

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្ដមឧបនាយករដ្ឋមន្ត្រី យឹម ឆៃលី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ. កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ១៧៤ . អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៥ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០០៦។

# សម្រេច

**មាត្រា ១ ._**

បង្កើត **គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ** ហៅកាត់ថា **គ.ជ.គ.ប.អ** ជាភាសាអង់គ្លេសហៅថា National Climate Change Committee (NCCC) ក្នុងទិសដៅរៀបចំ សម្របសម្រួល និងតាមដានពិនិត្យការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ បរិធានច្បាប់ ផែនការ និងកម្មវិធីនានា របស់រាជរដ្ឋាភិបាលសំដៅឆ្លើយតបទៅនឹងបញ្ហាប្រែប្រួលអាកាសធាតុក្នុងប្រទេស រួមចំណែកការពារបរិស្ថាន និងធនធានធម្មជាតិ ដើម្បីឱ្យបានដឹងជាមុន និងទប់ស្កាត់ការប្រែប្រួលអាកាសធាតុបណ្តាលមកពីមនុស្ស ដែលអាចបង្កឥទ្ធិពលអវិជ្ជមានចំពោះសុខុមាលភាពនៃមនុស្សជាតិ ។

**មាត្រា ២ ថ្មី ._**

**គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ** ជាយន្តការអន្តរក្រសួង មានចរិតលក្ខណៈ អន្តរវិស័យ និងពហុជំនាញ ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១. សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា | | ប្រធានកិត្តិយស |
| ២. រដ្ឋមន្ត្រីក្រសួងបរិស្ថាន | | ប្រធាន |
| ៣. រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | មួយ (០១) រូប | អនុប្រធាន |
| ៤. រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | មួយ (០១) រូប | អនុប្រធាន |
| ៥. រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | មួយ (០១) រូប | អនុប្រធាន |
| ៦. រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | មួយ (០១) រូប | សមាជិក |
| ៧. អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | មួយ (០១) រូប | សមាជិក |
| ៨. អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | មួយ (០១) រូប | សមាជិក |
| ៩. អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | មួយ (០១) រូប | សមាជិក |
| ១០. អនុរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | មួយ (០១) រូប | សមាជិក |
| ១១. អនុរដ្ឋលេខាធិការក្រសួងផែនការ | មួយ (០១) រូប | សមាជិក |
| ១២. អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | មួយ (០១) រូប | សមាជិក |
| ១៣. អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | មួយ (០១) រូប | សមាជិក |
| ១៤. អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល | មួយ (០១) រូប | សមាជិក |
| ១៥. អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | មួយ (០១) រូប | សមាជិក |
| ១៦. អនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | មួយ (០១) រូប | សមាជិក |

| | | |
|---|---|---|
| ១៧. អនុរដ្ឋលេខាធិការក្រសួងព័ត៌មាន | មួយ (០១) រូប | សមាជិក |
| ១៨. អគ្គលេខាធិការរងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ | មួយ (០១) រូប | សមាជិក |
| ១៩. អគ្គលេខាធិការរងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | មួយ (០១) រូប | សមាជិក |
| ២០. អគ្គលេខាធិការរងគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា | មួយ (០១) រូប | សមាជិក |

**មាត្រា ៣ .-**

**គ.ជ.គ.ប.អ** មានតួនាទី និងភារកិច្ច សម្របសម្រួល និងសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ក្នុងទិសដៅដូចតទៅ :

- រៀបចំសេចក្តីព្រាងគោលនយោបាយ យុទ្ធសាស្ត្រ បរិធានច្បាប់ ផែនការ និងកម្មវិធីនានា ស្តីពីការប្រែប្រួលអាកាសធាតុ ដោយរួមទាំងផែនការជាតិកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងផែនការជាតិបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច
- ជំរុញ និងលើកទឹកចិត្តឱ្យមានការចូលរួមយ៉ាងទូលំទូលាយ ពីភាគីពាក់ព័ន្ធទាំងអស់ នៅក្នុងការរៀបចំ និងក្នុងការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ បរិធានច្បាប់ ផែនការ និងកម្មវិធីនានា ស្តីពីការប្រែប្រួលអាកាសធាតុ ឱ្យមានប្រសិទ្ធភាព ឆ្លើយតបទៅនឹងបណ្តាអាទិភាព និងគោលដៅអភិវឌ្ឍន៍របស់ជាតិ
- ជំរុញ និងលើកទឹកចិត្តការដាក់បញ្ចូលបញ្ហាប្រែប្រួលអាកាសធាតុទៅក្នុងគោលនយោបាយ យុទ្ធសាស្ត្រ បរិធានច្បាប់ ផែនការ និងកម្មវិធីនានា ដែលពាក់ព័ន្ធ
- កៀរគរធនធានដែលចាំបាច់ ពិសេសការទាក់ទាញជំនួយឥតសំណង សម្រាប់អនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ បរិធានច្បាប់ ផែនការ និងកម្មវិធីនានា ស្តីពីការប្រែប្រួលអាកាសធាតុ
- ជំរុញ និងលើកទឹកចិត្តការផ្ទេរបច្ចេកវិជ្ជាថាមពលសមស្រប និងថាមពលកកើតឡើងវិញ ការអភិរក្ស និងការកែលំអអាងផ្ទុកកាបូន
- កំណត់គោលជំហរ និងយុទ្ធសាស្ត្រជាតិ សម្រាប់ចូលរួមក្នុងកិច្ចចរចា នៃកិច្ចប្រជុំអន្តរជាតិនានា ស្តីពីការប្រែប្រួលអាកាសធាតុ
- ពិនិត្យ និងអនុម័តលើរបាយការណ៍ផ្លូវការនានារបស់ជាតិ ដែលតម្រូវឱ្យរៀបចំ នៅក្រោមអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ
- សម្របសម្រួលសកម្មភាពនានា ដែលពាក់ព័ន្ធនឹងការអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ពិធីសារនានាក្រោមអនុសញ្ញានេះ និងកិច្ចព្រមព្រៀងអន្តរជាតិនានា ស្តីពីការប្រែប្រួលអាកាសធាតុ ដែលភាគីកម្ពុជាបានចូលជាសមាជិករួចហើយ
- ទទួលបន្ទុកគ្រប់គ្រង និងសម្របសម្រួលការងារយន្តការអភិវឌ្ឍន៍ស្អាតនៃពិធីសារក្យូតូ នៅកម្ពុជា

- ធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ ការអនុវត្តអនុសញ្ញាស្តីពីការប្រែប្រួលអាកាសធាតុ និងដំណើរការចរចាថ្នាក់អន្តរជាតិ
- ជំរុញការអប់រំ ការយល់ដឹង ការបណ្តុះបណ្តាល និងការផ្សព្វផ្សាយព័ត៌មានដល់សាធារណជនទូទៅ ស្តីពីការប្រែប្រួលអាកាសធាតុ
- ចូលរួមក្នុងកិច្ចប្រជុំ សន្និសីទ និងសិក្ខាសាលាថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ ស្តីពីបញ្ហាដែលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ
- សម្របសម្រួល និងត្រួតពិនិត្យការអនុវត្តបណ្តាគម្រោង កម្មវិធី និងសកម្មភាពស្រាវជ្រាវនានា ដែលពាក់ព័ន្ធនឹងបញ្ហាប្រែប្រួលអាកាសធាតុនៅកម្ពុជា
- ពិនិត្យ និងអនុម័តលើផែនការការងារ និងរបាយការណ៍នានារបស់ **ក្រុមបច្ចេកទេសការងារប្រែប្រួលអាកាសធាតុ** ហៅកាត់ថា **ក.ប.ក.ប.អ** (Climate Change Technical Team: CCTT) ដែលនឹងត្រូវបង្កើតឡើង អនុលោមតាមមាត្រា ៤ នៃអនុក្រឹត្យនេះ
- ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ។

**មាត្រា ៤ .-**

**គ.ជ.ក.ប.អ** ត្រូវរៀបចំបង្កើត **ក្រុមបច្ចេកទេសការងារប្រែប្រួលអាកាសធាតុ** (**ក.ប.ក.ប.អ**)។ **ក.ប.ក.ប.អ** មានភារកិច្ចទទួលខុសត្រូវលើការងារបច្ចេកទេស និងលើកមតិយោបល់ ដែលទាក់ទងទៅនឹងការងារប្រែប្រួលអាកាសធាតុនៅកម្ពុជា ជូនដល់ **គ.ជ.ក.ប.អ** ក្នុងការបំពេញភារកិច្ច ដូចមានចែងក្នុងមាត្រា ៣ នៃអនុក្រឹត្យនេះ។

**ក.ប.ក.ប.អ** មានមន្ត្រីជំនាញ ជាតំណាងមកពីបណ្តាក្រសួង និងស្ថាប័នរបស់រាជរដ្ឋាភិបាល ដែលមានបេសកកម្មពាក់ព័ន្ធនឹងការងារប្រែប្រួលអាកាសធាតុ និងការអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ។**ក.ប.ក.ប.អ** មានទីតាំងនៅក្រសួងបរិស្ថាន។

**មាត្រា ៥ .-**

សមាជិក **គ.ជ.ក.ប.អ** ទាំងអស់ ត្រូវចូលរួមប្រជុំឱ្យបានទៀងទាត់ តាមការកោះអញ្ជើញរបស់ប្រធាន **គ.ជ.ក.ប.អ** ។ ក្នុងករណីប្រធានអវត្តមាន អនុប្រធានមួយរូបត្រូវដឹកនាំការប្រជុំ តាមការប្រគល់សិទ្ធិរបស់ប្រធាន។ អង្គការជាតិ អង្គការអន្តរជាតិដែលពាក់ព័ន្ធ អាចចូលរួមប្រជុំបាន តាមការអញ្ជើញរបស់ប្រធាន ឬអនុប្រធានទទួលសិទ្ធិ ។

**គ.ជ.ក.ប.អ** មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងបរិស្ថាន។

**មាត្រា ៦ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៧ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីនៃក្រសួងនិងប្រធាននៃស្ថាប័នដែលពាក់ព័ន្ធ ដូចមានចែងក្នុងមាត្រា ២ ត្រូវអនុវត្តអនុក្រឹត្យនេះ តាមសមត្ថកិច្ចរបស់ខ្លួន ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០៩

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រា ៧
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ..១៣៥..អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបំបែកនាយកដ្ឋាន និងតម្លើងការិយាល័យទៅជានាយកដ្ឋានជំនាញ ចំណុះអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ បំពេញបន្ថែមលើ អនុក្រឹត្យ លេខ ៣៧ អនក្រ.បក ចុះថ្ងៃទី ២៤ ខែមេសា ឆ្នាំ២០០៨

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ២០០៨ ស្តីពីការតម្លើងនាយកដ្ឋានការពារ និងអភិរក្សធម្មជាតិ ទៅជាអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## ស ម្រេ ច

**មាត្រា១:** –

ក- ត្រូវបានបំបែក នាយកដ្ឋានឧទ្យានជាតិ និង ដែនជម្រកសត្វព្រៃ ជា ០២នាយកដ្ឋាន គឺ :

**១- នាយកដ្ឋាន ឧទ្យានជាតិ**

**២- នាយកដ្ឋាន ដែនជម្រកសត្វព្រៃ**

ខ- ត្រូវបានតម្លើងការិយាល័យប្រែប្រួលអាកាសធាតុ ជា :

**- នាយកដ្ឋាន ប្រែប្រួលអាកាសធាតុ**

នាយកដ្ឋានជំនាញទាំងបី (០៣) ខាងលើនេះ ចំណុះឱ្យអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ របស់ក្រសួងបរិស្ថាន បំពេញបន្ថែមលើអនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ២០០៨ ស្តីពីការតម្លើងនាយកដ្ឋានការពារ និងអភិរក្សធម្មជាតិ ទៅជា អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ។

**មាត្រា២:** –

**នាយកដ្ឋាន ឧទ្យានជាតិ** មានភារកិច្ច :

- រៀបចំយុទ្ធសាស្ត្រ ផែនការសកម្មភាព និងគោលការណ៍ណែនាំបច្ចេកទេស សម្រាប់គ្រប់គ្រងតំបន់ឧទ្យានជាតិ តំបន់ការពារទេសភាព តំបន់ប្រើប្រាស់ច្រើនយ៉ាងដងវែង និងតំបន់ប្រើប្រាស់ច្រើនយ៉ាងសំឡូត និងតំបន់រុក្ខឧទ្យានជាតិ
- រៀបចំការកំណត់ព្រំប្រទល់ ធ្វើផែនទីតំបន់ការពារធម្មជាតិខាងលើ ព្រមទាំងធ្វើការកំណត់តំបន់គ្រប់គ្រងនៅតាមតំបន់ការពារធម្មជាតិនីមួយៗ ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ឬ អង្គការជាតិ-អន្តរជាតិ
- សិក្សា ស្រាវជ្រាវ និងរៀបចំទិន្នន័យប្រភេទសត្វ រុក្ខជាតិ ប្រភេទដែលកម្រ និងប្រភេទជិតផុតពូជនៅក្នុងតំបន់ឧទ្យានជាតិ តំបន់ការពារទេសភាព តំបន់ប្រើប្រាស់ច្រើនយ៉ាងដងវែង និងតំបន់ប្រើប្រាស់ច្រើនយ៉ាងសំឡូត
- រៀបចំគម្រោងកម្មវិធីស្វែងរកជំនួយថវិកា និងបច្ចេកទេសពីបណ្តាប្រទេស ឬ អង្គការជាតិ អន្តរជាតិនានា ដើម្បីគាំទ្រដល់ការគ្រប់គ្រងតំបន់ការពារធម្មជាតិនីមួយៗខាងលើ បានប្រកបដោយនិរន្តរភាព
- ត្រួតពិនិត្យលិខិតអនុញ្ញាត និងឯកសារផ្សេងៗ ដែលបានកំណត់ដោយច្បាប់ ស្តីពីតំបន់ការពារធម្មជាតិ និងមានវិធានការទប់ស្កាត់ភ្លើងឆេះព្រៃក្នុងតំបន់ការពារធម្មជាតិនីមួយៗខាងលើ
- ធ្វើការអប់រំ ផ្សព្វផ្សាយដល់សាធារណៈជនក្នុងការចូលរួមថែរក្សា ការពារធនធានធម្មជាតិក្នុងតំបន់ឧទ្យានជាតិ តំបន់ការពារទេសភាព តំបន់ប្រើប្រាស់ច្រើនយ៉ាងដងវែង តំបន់ប្រើប្រាស់ច្រើនយ៉ាងសំឡូត និងតំបន់រុក្ខឧទ្យានជាតិ និងផ្សព្វផ្សាយ ត្រួតពិនិត្យការអនុវត្តច្បាប់ អនុក្រឹត្យ បរិធានច្បាប់នានា និងគោលការណ៍ណែនាំបច្ចេកទេស ក្នុងការគ្រប់គ្រងតំបន់ការពារធម្មជាតិទាំងនេះ
- ចាត់វិធានការណ៍ដើម្បីស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបបទល្មើសលើធនធានធម្មជាតិ ក្នុងតំបន់ការពារធម្មជាតិខាងលើ និងកសាងសំណុំរឿងបញ្ជូនទៅតុលាការ ក្នុងនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ស្របតាមនីតិវិធីច្បាប់ ។

នាយកដ្ឋានឧទ្យានជាតិ ដឹកនាំដោយប្រធាននាយកដ្ឋាន ០១រូប និងអមដោយអនុប្រធាននាយកដ្ឋានជាជំនួយការតាមការចាំបាច់ ។

មាត្រា៧: -

**នាយកដ្ឋាន ដែនជម្រកសត្វព្រៃ** មានភារកិច្ច :

- រៀបចំយុទ្ធសាស្ត្រ ផែនការសកម្មភាព និងគោលការណ៍ណែនាំបច្ចេកទេស សម្រាប់គ្រប់គ្រងតំបន់ដែនជម្រកសត្វព្រៃ និងរៀបចំការកំណត់ព្រំប្រទល់ ធ្វើផែនទីតំបន់ដែនជម្រកសត្វព្រៃ ព្រមទាំងធ្វើការកំណត់តំបន់គ្រប់គ្រងនៅតាមតំបន់ដែនជម្រកសត្វព្រៃនីមួយៗ ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ឬ អង្គការជាតិ-អន្តរជាតិ
- សិក្សា ស្រាវជ្រាវ និងរៀបចំទិន្នន័យប្រភេទសត្វ រុក្ខជាតិ ប្រភេទដែលកម្រ និងប្រភេទជិតផុតពូជនៅក្នុងតំបន់ដែនជម្រកសត្វព្រៃ
- រៀបចំគម្រោងកម្មវិធីស្វែងរកជំនួយថវិកា និងបច្ចេកទេសពីបណ្តាប្រទេស ឬ អង្គការជាតិ អន្តរជាតិនានា ដើម្បីគាំទ្រដល់ការគ្រប់គ្រងតំបន់ដែនជម្រកសត្វព្រៃនីមួយៗបានប្រកបដោយនិរន្តរភាព
- ត្រួតពិនិត្យលិខិតអនុញ្ញាត និងឯកសារផ្សេងៗ ដែលបានកំណត់ដោយច្បាប់ ស្តីពីតំបន់ការពារធម្មជាតិ និងមានវិធានការទប់ស្កាត់ភ្លើងឆេះព្រៃក្នុងតំបន់ដែនជម្រកសត្វព្រៃនីមួយៗ
- ធ្វើការអប់រំផ្សព្វផ្សាយដល់សាធារណៈជនក្នុងការចូលរួមថែរក្សា ការពារធនធានធម្មជាតិក្នុងតំបន់ដែនជម្រកសត្វព្រៃនីមួយៗ និងផ្សព្វផ្សាយ ត្រួតពិនិត្យការអនុវត្តច្បាប់ អនុក្រឹត្យ បរិធានច្បាប់នានា និងគោលការណ៍ណែនាំបច្ចេកទេសក្នុងការគ្រប់គ្រងតំបន់ដែនជម្រកសត្វព្រៃនីមួយៗ
- ចាត់វិធានការណ៍ដើម្បីស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបបទល្មើសលើធនធានធម្មជាតិ ក្នុងតំបន់ដែនជម្រកសត្វព្រៃនីមួយៗ និងកសាងសំណុំរឿងបញ្ជូនទៅតុលាការក្នុងនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ស្របតាមនីតិវិធីច្បាប់។

នាយកដ្ឋានដែនជម្រកសត្វព្រៃ ដឹកនាំដោយប្រធាននាយកដ្ឋាន ០១រូប និងអមដោយអនុប្រធាននាយកដ្ឋាន ជាជំនួយការតាមការចាំបាច់។

មាត្រា៨: -

**នាយកដ្ឋាន ប្រែប្រួលអាកាសធាតុ** មានភារកិច្ច :

- រៀបចំផែនការយុទ្ធសាស្ត្រជាតិ ផែនការសកម្មភាព និងគោលនយោបាយ បរិធានច្បាប់នានាពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ
- អនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ ពិធីសារ និងសេចក្តីសម្រេចនានា ដែលនៅក្រោមអនុសញ្ញានេះ
- រៀបចំរបាយការណ៍ជាតិ និងសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ នៃព្រះរាជាណាចក្រកម្ពុជា ក្រោមអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ
- សិក្សាវាយតម្លៃសក្តានុពលកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងជម្រុញការអនុវត្តគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់នៅព្រះរាជាណាចក្រកម្ពុជា ដោយប្រើប្រាស់បច្ចេកវិទ្យាសមស្រប

- សិក្សាវាយតម្លៃភាពងាយរងគ្រោះ និងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ព្រមទាំងជម្រុញការអនុវត្តគម្រោងបន្សាំនឹងការប្រែប្រួលអាកាសធាតុនៅព្រះរាជាណាចក្រកម្ពុជា
- ជម្រុញការបញ្ជ្រាបបញ្ហាប្រែប្រួលអាកាសធាតុទៅក្នុងផែនការអភិវឌ្ឍន៍ជាតិ និងផែនការតាមវិស័យ និងសម្របសម្រួលការអនុវត្តគម្រោងយន្តការអភិវឌ្ឍន៍ស្អាត និងគម្រោងឥណទានកាបោននៅព្រះរាជាណាចក្រកម្ពុជា។
- ជម្រុញការងារសិក្សាស្រាវជ្រាវ អប់រំ ផ្សព្វផ្សាយ បណ្តុះបណ្តាល រៀបចំសិក្ខាសាលា កិច្ចប្រជុំនានា សំដៅលើកកម្ពស់ការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ និងលើកទឹកចិត្តឱ្យមានការចូលរួមពីសហគមន៍មូលដ្ឋាន ក្នុងការអនុវត្តគម្រោងឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ
- លើកសំណើគម្រោង និងកម្មវិធីនានា ព្រមទាំងសម្របសម្រួល តាមដាន និងវាយតម្លៃការអនុវត្តគម្រោងកម្មវិធីទាំងអស់ ដែលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ នៅព្រះរាជាណាចក្រកម្ពុជា
- កៀរគរធនធានដែលចាំបាច់ ពិសេសការទាក់ទាញជំនួយឥតសំណង សម្រាប់អនុវត្តគោលនយោបាយយុទ្ធសាស្ត្រ បរិធានច្បាប់ ផែនការ និងកម្មវិធីនានា ស្តីពីការប្រែប្រួលអាកាសធាតុ
- បំពេញតួនាទីជាស្ថាប័នបង្គោលរបស់អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ ពិធីសារក្យូតូ យន្តការអភិវឌ្ឍន៍ស្អាត សេចក្តីសម្រេចនានា និងក្រុមប្រឹក្សាអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ ព្រមទាំងរៀបចំគោលជំហរជាតិ សម្រាប់ការចរចាពាក់ព័ន្ធ
- បំពេញតួនាទីជាលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ
- សហការជាមួយស្ថាប័នពាក់ព័ន្ធ ក្នុងការរៀបចំបង្កើត និងគ្រប់គ្រងមូលនិធិប្រែប្រួលអាកាសធាតុ និងគោលនយោបាយឥណទានកាបោន
- ពង្រឹងកិច្ចសហការជាមួយស្ថាប័នពាក់ព័ន្ធជាតិ ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងផ្នែកឯកជន ក្នុងការអនុវត្តវិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ក៏ដូចជាអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ ឱ្យមានប្រសិទ្ធភាព
- រៀបចំរបាយការណ៍សកម្មភាព និងលទ្ធផលការងារ ជូនរាជរដ្ឋាភិបាល ក្រសួងបរិស្ថាន ស្ថាប័នជាតិ-អន្តរជាតិ និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ។

នាយកដ្ឋាន ប្រែប្រួលអាកាសធាតុ ដឹកនាំដោយប្រធាននាយកដ្ឋាន ០១រូប និងអមដោយអនុប្រធាននាយកដ្ឋាន ជាជំនួយការតាមការចាំបាច់។

**មាត្រា៩:-**

ការរៀបចំ និងការប្រព្រឹត្តទៅ របស់នាយកដ្ឋានជំនាញចំណុះអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិទាំងអស់ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន។

មាត្រា៦: -

ត្រូវបាននិរាករណ៍ មាត្រាទី៥ នៃអនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ២០០៨ ស្តីពីការតម្លើងនាយកដ្ឋានការពារ និងអភិរក្សធម្មជាតិ ទៅជា អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ។

មាត្រា៧ -

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី និងរដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ។

មាត្រា៨ -

អនុក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១[illegible] ខែ តុលា ឆ្នាំ ២០០៩

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីជម្រាបជូន សម្តេចនាយករដ្ឋមន្ត្រី

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**បណ្ឌិត ម៉ុក ម៉ារ៉េត**

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៧
- រាជកិច្ច
- ឯកសារ. កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៧៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់សាកលវិទ្យាល័យបញ្ញាជាតិ

* * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញអនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខណវិនិច្ឆ័យ នៃការបង្កើតសាកលវិទ្យាល័យ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

# សម្រេច

**មាត្រា ១.-**

ទទួលស្គាល់ការបង្កើតគ្រឹះស្ថានឧត្តមសិក្សាឯកជនមួយ ដែលមានឈ្មោះថា សាកលវិទ្យាល័យ បញ្ញាជាតិ **Panha Chiet University** សរសេរកាត់ជាភាសាខ្មែរ ស.ប.ជ និងសរសេរកាត់ជាភាសា អង់គ្លេស **P.C.U** ។

**មាត្រា ២.-**

ស.ប.ជ មានទីតាំងស្ថិតនៅអគារលេខ ២០-២៤ -១៣ ផ្លូវលេខ ២១០ សង្កាត់ ទឹកល្អក់៣ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ និងស្ថិតនៅក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៣.-**

ស.ប.ជ ធ្វើការបណ្តុះបណ្តាលកម្រិត បរិញ្ញាបត្ររង និងបរិញ្ញាបត្រ លើមហាវិទ្យាល័យប្រាំ :

១- មហាវិទ្យាល័យ សិល្បៈ មនុស្សសាស្ត្រ និងភាសា

២- មហាវិទ្យាល័យ គណិតវិទ្យា និងវិទ្យាសាស្ត្រ

៣- មហាវិទ្យាល័យ វិទ្យាសាស្ត្រសង្គម

៤- មហាវិទ្យាល័យ ធុរកិច្ច និងសេដ្ឋកិច្ច

៥- មហាវិទ្យាល័យ អប់រំ ។

ស.ប.ជ ត្រូវរៀបចំកម្មវិធីសិក្សាលម្អិត តាមកម្រិត និងមុខជំនាញ ដើម្បីសុំការឯកភាព ពីក្រសួងអប់រំ យុវជន និងកីឡា មុននឹងចាប់ផ្តើមដំណើរការបណ្តុះបណ្តាល ។ ទៅអនាគតសាកលវិទ្យាល័យនេះ អាចបើកសាខាមហាវិទ្យាល័យថ្មី មុខជំនាញថ្មី កម្រិតឬថ្នាក់ថ្មី ប្រភេទបណ្តុះបណ្តាលថ្មី ប្តូរឈ្មោះថ្មី ឬទីតាំងថ្មី ដោយរៀបចំសំណុំបែបបទ សុំការអនុញ្ញាត ពីក្រសួង អប់រំ យុវជន និងកីឡា ។

**មាត្រា ៤.-**

ស.ប.ជ ត្រូវមានក្រុមប្រឹក្សាភិបាលមួយ ដើម្បីពិនិត្យ និងសម្រេច លើគោលនយោបាយ ផែនការអភិវឌ្ឍ កម្មវិធីសិក្សា និងការងារបច្ចេកទេសពាក់ព័ន្ធដទៃទៀត ។ តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងជាក់ស្តែង នៃ ស.ប.ជ ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល និងមានការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៥.-**

សាកលវិទ្យាធិការ ស.ប.ជ មានភារកិច្ច :

- ទទួលខុសត្រូវចំពោះមុខច្បាប់ ក្នុងការគ្រប់គ្រង ស.ប.ជ និងធានាឱ្យមានសុវត្ថិភាពសណ្តាប់ធ្នាប់សង្គម
- គោរព និងអនុវត្តតាមបទដ្ឋាន ដែលពាក់ព័ន្ធនឹងការងារបណ្តុះបណ្តាល របស់ក្រសួងអប់រំ យុវជន និង កីឡា និងច្បាប់របស់រាជរដ្ឋាភិបាល សំដៅធានាគុណភាពអប់រំ
- ធ្វើរបាយការណ៍ប្រចាំឆ្នាំ មកនាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា តាមការកំណត់ ។

**មាត្រា ៦.-**

និស្សិត ស.ប.ជ ដែលបានរៀនចប់កម្មវិធីសិក្សា និងទទួលបានជោគជ័យ ក្នុងការប្រឡងបញ្ចប់ការសិក្សាត្រូវទទួលសញ្ញាបត្រតាមកម្រិត និងមុខជំនាញដែលបានសិក្សា។ សញ្ញាបត្រនេះ ផ្តល់ឱ្យដោយ ស.ប.ជ ហើយ ត្រូវបានទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណី ស.ប.ជ បំពេញ និងអនុវត្តបានតាមគោលការណ៍ និងបទដ្ឋានរបស់ក្រសួង អប់រំ យុវជន និងកីឡា ។

**មាត្រា ៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ប្រធានស្ថាប័នពាក់ព័ន្ធ និងក្រុមប្រឹក្សាភិបាល រួមជាមួយសាកលវិទ្យាធិការ នៃ ស.ប.ជ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានីភ្នំពេញ
- ដូចមាត្រា ៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៧៧ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការបង្កើតក្រុមប្រឹក្សានីតិកម្ម នៃក្រសួងមហាផ្ទៃ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ

-បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៥ ស្តីពីការបង្កើតក្រុមប្រឹក្សានីតិកម្ម និងនាយកដ្ឋានទំនាក់ទំនងអន្តរជាតិ ចំណុះក្រសួងមហាផ្ទៃ

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ .-**

ត្រូវបានបង្កើតក្រុមប្រឹក្សានីតិកម្មនៃក្រសួងមហាផ្ទៃ ដើម្បីជួយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងការពិនិត្យស្រាវជ្រាវ និងកសាងលិខិតបទដ្ឋានគតិយុត្តនានា ដែលពាក់ព័ន្ធនឹងក្រសួងមហាផ្ទៃ រួមចំណែកក្នុងការអនុវត្តកម្មវិធីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌របស់រាជរដ្ឋាភិបាល ។

**មាត្រា២ .-**

ក្រុមប្រឹក្សានីតិកម្មរបស់ក្រសួងមហាផ្ទៃ មានភារកិច្ច ÷

-សហការជាមួយអង្គភាពពាក់ព័ន្ធចំណុះក្រសួងមហាផ្ទៃ ក្នុងការលើកផែនការ ការងារកសាងលិខិតបទដ្ឋានគតិយុត្ត និងឯកសារចាំបាច់ផ្សេងទៀតរបស់ក្រសួងមហាផ្ទៃ ឱ្យស្របតាមអាទិភាព នៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល

-សហការសិក្សាស្រាវជ្រាវជាមួយអង្គភាពពាក់ព័ន្ធចំណុះក្រសួងមហាផ្ទៃ និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីតាក់តែង រៀបរៀងសេចក្តីព្រាង លើកគម្រោងនៃការតាក់តែង កសាង និងកែសម្រួលលិខិតបទដ្ឋានគតិយុត្តនានាដែលបំរើសកម្មភាពរបស់ក្រសួងមហាផ្ទៃ

-ពិនិត្យខ្លឹមសារសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តនានា ដែលអង្គភាពទាំងឡាយចំណុះក្រសួងមហាផ្ទៃបានតាក់តែងរួចហើយ មុននឹងដាក់ឆ្លងមតិថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ ដោយធ្វើការសិក្សាបំពេញបន្ថែមខ្លឹមសារដែលនៅចន្លោះប្រហោង ឬកាត់បន្ថយខ្លឹមសារណាដែលយល់ឃើញថាមិនសមស្រប

-សហការតាមដាន ត្រួតពិនិត្យ ដីកា និងសេចក្តីសម្រេចនានារបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-សិក្សា និងតាមដានលិខិតបទដ្ឋានគតិយុត្តទាំងឡាយដែលមិនសមស្របទៅនឹងសភាពការណ៍ជាក់ស្តែងដើម្បីលើកយោបល់ជូនថ្នាក់ដឹកនាំក្រសួងធ្វើវិសោធនកម្មឱ្យស្របតាមស្ថានភាពអភិវឌ្ឍន៍នៃប្រទេសជាតិ

-សិក្សា និងផ្តល់យោបល់ជូនថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ អំពីសេចក្តីព្រាងលិខិតូបករណ៍នានា ដែលពាក់ព័ន្ធនឹងក្រសួងមហាផ្ទៃ

-តាមដានលើការអនុវត្ត និងផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តនានា

-សហការចាត់ចែងរៀបចំបំពេញបែបបទក្នុងការបញ្ជូនសេចក្តីព្រាងច្បាប់ ឬអនុក្រឹត្យនានាទៅរាជរដ្ឋាភិបាលក្រោយពីមានការសម្រេចពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃរួចហើយ

-សិក្សាស្រាវជ្រាវ តាក់តែងសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តនានា តាមការចាត់តាំងរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

-ចូលរួមជាមួយគណៈកម្មាធិការ ឬ ក្រុមការងារតាក់តែងលិខិតបទដ្ឋានគតិយុត្ត ឬអង្គភាពជំនាញ ឬ ក្រសួងស្ថាប័ននានា តាមការចាត់តាំងរបស់ថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ

-ចូលរួមក្នុងការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ស្របតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល

-សហការរៀបចំការបណ្តុះបណ្តាលដល់មន្ត្រីក្រោមឱវាទរបស់ក្រសួងមហាផ្ទៃលើការងារពាក់ព័ន្ធនឹងច្បាប់

-តំណាងឱ្យក្រសួងមហាផ្ទៃចូលរួមប្រជុំជាមួយក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល តាមការចាត់តាំងពីថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ

-គ្រប់គ្រងបណ្ណាល័យក្រុមប្រឹក្សានីតិកម្មក្រសួងមហាផ្ទៃ និងចែកផ្សាយសៀវភៅរាជកិច្ច និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធដល់ការងាររដ្ឋបាល នគរបាលជាតិនៅទីស្តីការក្រសួងមហាផ្ទៃ និងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំសង្កាត់

-ចងក្រងបោះពុម្ពជាសៀវភៅច្បាប់សម្រាប់ចែកចាយផ្សព្វផ្សាយ

-សហការជាមួយអង្គភាពពាក់ព័ន្ធចំណុះក្រសួងមហាផ្ទៃ ទាំងនៅថ្នាក់កណ្តាល និងថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដើម្បីផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តនានាដែលចាំបាច់

-ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត តាមការចាត់តាំងរបស់ថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ។

**មាត្រា៣ .-**

រចនាសម្ព័ន្ធរបស់ក្រុមប្រឹក្សានីតិកម្ម ត្រូវបានកំណត់ដូចខាងក្រោម ÷

-ក្រុមស្រាវជ្រាវលិខិតបទដ្ឋានគតិយុត្តនគរបាល

-ក្រុមស្រាវជ្រាវលិខិតបទដ្ឋានគតិយុត្តរដ្ឋបាល

-ក្រុមស្រាវជ្រាវលិខិតបទដ្ឋានគតិយុត្តក្រសួង ស្ថាប័ន នានា

-ក្រុមស្រាវជ្រាវលិខិតបទដ្ឋានគតិយុត្តអន្តរជាតិ

-លេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម

**មាត្រា៤ .-**

ក្រុមប្រឹក្សានីតិកម្ម មានសមាសភាព ប្រធាន អនុប្រធាន និងសមាជិក។

ក្រុមប្រឹក្សានីតិកម្មត្រូវបានដឹកនាំដោយប្រធាន ០១រូប និងអនុប្រធានមួយចំនួនជាជំនួយការ។

ប្រធានក្រុមប្រឹក្សានីតិកម្ម មានថ្នាក់ស្មើអនុរដ្ឋលេខាធិការ អនុប្រធានក្រុមប្រឹក្សានីតិកម្ម មានថ្នាក់ស្មើអគ្គនាយក នៃអគ្គនាយកដ្ឋាននានារបស់ក្រសួងមហាផ្ទៃ។

សមាជិកក្រុមប្រឹក្សានីតិកម្មគ្រប់រូប មានថ្នាក់ស្មើប្រធាននាយកដ្ឋាន នៃអគ្គនាយកដ្ឋានចំណុះក្រសួងមហាផ្ទៃ។

**មាត្រា៥ .-**

សមាជិកក្រុមប្រឹក្សានីតិកម្ម ត្រូវបានជ្រើសរើសក្នុងចំណោមមន្ត្រីជាន់ខ្ពស់ នៃក្របខ័ណ្ឌរបស់ក្រសួងមហាផ្ទៃ ដែលមានសញ្ញាប័ត្រ ចាប់ពីបរិញ្ញាប័ត្រឡើងទៅ និងមានបទពិសោធន៍លើការងារកសាងលិខិតបទដ្ឋានគតិយុត្ត។

**មាត្រា៦ .-**

សមាជិកក្រុមប្រឹក្សានីតិកម្មម្នាក់ៗ ត្រូវបានចាត់តាំងបញ្ចូលទៅក្នុងក្រុមស្រាវជ្រាវនីមួយៗ។ ក្រុមស្រាវជ្រាវនីមួយៗត្រូវមានសមាជិកក្រុមប្រឹក្សានីតិកម្មយ៉ាងតិច ៥រូប ដឹកនាំដោយប្រធាន ១រូប ចាត់តាំងឡើងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃតាមសំណើរបស់ប្រធានក្រុមប្រឹក្សានីតិកម្ម។

ក្នុងករណីប្រធានអវត្តមាន ប្រធានក្រុមប្រឹក្សានីតិកម្ម ត្រូវចាត់តាំងសមាជិកក្រុមប្រឹក្សានីតិកម្មណាម្នាក់ នៅក្នុងក្រុមស្រាវជ្រាវជាមួយ ជាប្រធានស្តីទីជំនួស។

**មាត្រា៧ .-**

តួនាទី និងភារកិច្ចរបស់ក្រុមស្រាវជ្រាវនីមួយៗ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ។

**មាត្រា៨ .-**

លេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម ជាសេនាធិការឱ្យក្រុមប្រឹក្សានីតិកម្ម សម្រាប់ចាត់ចែងកិច្ចការរដ្ឋបាលទូទៅ ធ្វើកំណត់ហេតុគ្រប់ពេលប្រជុំរបស់ក្រុមប្រឹក្សានីតិកម្ម និងធ្វើកិច្ចការផ្សេងៗ តាមសំណូមពររបស់ក្រុមប្រឹក្សានីតិកម្ម។

លេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម មានថ្នាក់ស្មើនាយកដ្ឋានចំណុះអគ្គនាយកដ្ឋាននានារបស់ក្រសួងមហាផ្ទៃ។

តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់លេខាធិការដ្ឋានត្រូវកំណត់ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ។

**មាត្រា៩ .-**

លេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម ដឹកនាំដោយប្រធាន ០១រូប និងអនុប្រធានមួយចំនួនជាជំនួយការ។

ប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម មានថ្នាក់ស្មើនឹងប្រធាននាយកដ្ឋាននានាចំណុះក្រសួងមហាផ្ទៃ។

អនុប្រធានលេខាធិការដ្ឋាន មានថ្នាក់ស្មើនឹងអនុប្រធាននាយកដ្ឋានចំណុះក្រសួងមហាផ្ទៃ។

**មាត្រា១០ .-**

ប្រធានក្រុមប្រឹក្សានីតិកម្ម មានសិទ្ធិអញ្ជើញថ្នាក់ដឹកនាំអង្គភាពនានាក្រោមឱវាទក្រសួងមហាផ្ទៃ មកចូលរួមកិច្ចប្រជុំការងារ ឬមកបំភ្លឺលើលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា។

**មាត្រា១១ .-**

មាត្រាទាំងឡាយនៃអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៥ ដែលពាក់ព័ន្ធនឹងតួនាទីភារកិច្ច និងរចនាសម្ព័ន្ធរបស់ក្រុមប្រឹក្សានីតិកម្ម និងបទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងស្ថាប័នពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការនៃរាជរដ្ឋាភិបាល
- ដូចមាត្រា ១២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**បានយកសេចក្តីជម្រាបជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីចុះហត្ថលេខា**

**ស ខេង**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ១.៥.៣.២..អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិតសភាកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៥ ស្តីពីការកែសម្រួល មាត្រា៤ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ និង មាត្រា២០ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិតសភាកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៤៤អនក្រ/បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រាជបណ្ឌិតសភាកម្ពុជា
- តាមសំណើរបស់ប្រធានរាជបណ្ឌិតសភាកម្ពុជា

## សម្រេច

**មាត្រា១:** ត្រូវបានតែងតាំង លោក **តឹក មេង** ជាប្រធានផ្នែកទំនាក់ទំនងកសិកម្ម បរិស្ថាន និងថាមពល នៃវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិនៃរាជបណ្ឌិតសភាកម្ពុជា មានឋានៈស្មើ **ប្រធាននាយកដ្ឋាន** ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានរាជបណ្ឌិតសភាកម្ពុជា រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ [illegible] ៧ ឆ្នាំ ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:១៥៣៤.អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពីការផ្តល់មេដាយការងារ

ទាក់ទង

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងសាធារណការ និងដឹកជញ្ជូន

**សម្រេច**

**មាត្រា១.-**

ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនមន្ត្រីរាជការ ចំនួន០៤រូប នៃក្រសួងសាធារណការ និង ដឹកជញ្ជូន ដែលមានស្នាដៃល្អក្នុងការជួយការងារស្ថាបនាកំណាត់ផ្លូវជាតិ លេខ ៥-៦ (សៀមរាប-ប៉ោយប៉ែត) និង ស្ពាន លូ លើកំណាត់ផ្លូវជាតិ លេខ៥៦ និង លេខ ៦៨ ( ស៊ីសុផុន-សំរោង-ក្រឡាញ់ ) រហូតបញ្ចប់ជាស្ថាពរ ដូចមានរាយនាមខាងក្រោម :-

| | | | |
|---|---|---|---|
| ១-លោកស្រី | **ហង់** | **សុជីវី** | អនុប្រធានការិ.នៃនាយកដ្ឋានសំណង់ផ្លូវអាកាសនិងជាប្រធានគណនេយ្យ គំរោង |
| ២-លោក | **សៅ** | **ព្រហ្មរក្ស** | វិស្វករស្ពាន ផ្លូវ ប្រចាំគំរោង |
| ៣-លោក | **សុខ** | **សំអន** | វិស្វករស្ពាន ផ្លូវ ប្រចាំគំរោង |
| ៤-លោកស្រី | **ទ្រី** | **សុខណៃ** | |

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/ HKR

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ [illegible] ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>**កន្លែងទទួល :**</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ១៥៣៥. អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា ជូនសប្បុរសជន ចំនួន ០៣រូប ដែលមានស្នាដៃល្អក្នុងការខិតខំស្វែងរកថវិកា ជួយកសាងអគារសិក្សា និងសមិទ្ធផលនានា ក្នុងវិស័យអប់រំ នៅតាមបណ្តាខេត្តមួយចំនួន សរុបអស់ទឹកប្រាក់ ចំនួន ២៤០.០០០ ដុល្លារអាមេរិក ដូចមានរាយនាមខាងក្រោម ៖

១- លោក **ហ៊ិន ស៊ាងហុង** សប្បុរសជន

២- លោក **ទ្រី សុធារិទ្ធ** សប្បុរសជន

៣- លោក **អ៊ិន សុខហេង** សប្បុរសជន

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១២ តុលា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

**កន្លែងទទួលៈ**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៥៧៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការដំឡើងឋានន្តរស័ក្តិមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៥ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មិនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច
- តាមសំណើរបស់រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

## ស ម្រេ ច

មាត្រា ១ ៖ ត្រូវបានដំឡើងឋានន្តរស័ក្តិមន្ត្រីរាជការក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលរបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-

**ព្រឹទ្ធសភា និងអធិការកិច្ច** ដូចមានរាយនាមខាងក្រោម ៖

| | | | | |
|---|---|---|---|---|
| ១ | **ទើង ម៉ុនលាង** | ប | ពីអនុមន្ត្រី ថ្នាក់លេខ ៤ | ទៅវរមន្ត្រី ថ្នាក់លេខ ៦ |
| ២ | **កែវ គង់** | ប | ពីអនុមន្ត្រី ថ្នាក់លេខ ៧ | ទៅវរមន្ត្រី ថ្នាក់លេខ ៨ |
| ៣ | **ចាន់ ស្មើ** | ប | ពីអនុមន្ត្រី ថ្នាក់លេខ ៨ | ទៅវរមន្ត្រី ថ្នាក់លេខ ៩ |
| ៤ | **លី គីមសី** | ប | ពីអនុមន្ត្រី ថ្នាក់លេខ ៩ | ទៅវរមន្ត្រី ថ្នាក់លេខ ១០ |
| ៥ | **កែវ ផល្លា** | ប | ពីអនុមន្ត្រី ថ្នាក់លេខ ៩ | ទៅវរមន្ត្រី ថ្នាក់លេខ ១០ |
| ៦ | **នួន ណាំ** | ប | ពីអនុមន្ត្រី ថ្នាក់លេខ ១០ | ទៅវរមន្ត្រី ថ្នាក់លេខ ១០ |
| ៧ | **ពិន អ៊ិច** | ប | ពីអនុមន្ត្រី ថ្នាក់លេខ ១០ | ទៅវរមន្ត្រី ថ្នាក់លេខ ១០ |
| ៨ | **អ៊ុក ថុន** | ប | ពីអនុមន្ត្រី ថ្នាក់លេខ ១១ | ទៅវរមន្ត្រី ថ្នាក់លេខ ១០ |
| ៩ | **ហេង លីមន្រ្ទី** | ប | ពីអនុមន្ត្រី ថ្នាក់លេខ ១១ | ទៅវរមន្ត្រី ថ្នាក់លេខ ១០ |

**មាត្រា ២ ៖** មន្ត្រីដែលត្រូវបានដំឡើងឋានន្តរស័ក្តិដូចមានឈ្មោះក្នុងមាត្រា ១ ខាងលើ ត្រូវបានរក្សាទុកអតីតភាពសម្រាប់ឡើងថ្នាក់តាមវេនជ្រើសរើស និងវេនអតីតភាពដដែល ។

**មាត្រា ៣ ៖** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៥៧៧.អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញអនុក្រឹត្យ លេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងផែនការ

## សម្រេច

**មាត្រា ១ :** តែងតាំង លោក **មាន់ សារ៉ាត** ជាទីប្រឹក្សាក្រសួងផែនការ មានឋានៈស្មើ **អគ្គនាយករង** ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១៥៣៤ . អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពីការជូនមេដាយស្ថាបនាជាតិ**

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

**សម្រេច**

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនអង្គការ ចំនួន០៣ ដែលបានជួយឧបត្ថម្ភថវិកា ក្នុងការជួយកសាងអគារសិក្សា ០១ខ្នង មាន៣បន្ទប់ និងសមិទ្ធផលនានា នៅសាលាបឋមសិក្សាអង្គញ ឃុំត្រពាំងឡូច ស្រុកទ្រាំង ខេត្តតាកែវ សរុបថវិកាចំនួន ៥០.០០០ ដុល្លារអាមេរិក ដូចមានរាយនាមខាងក្រោម ៖

១- អង្គការ IVUSA

២- អង្គការ YAMATAKARAC

៣- អង្គការ Risyou Kousei-Kai

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាល ខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

**កន្លែងទទួលៈ**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា១ និងមាត្រា២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ ១៥៣៩ អនក្រ.បក**

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយសុវត្ថារា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍

## សម្រេច

**មាត្រា១ .-**

ត្រូវបានបំពាក់ **មេដាយសុវត្ថារា** ថ្នាក់ **ធិបឌិន្ទ** ជូនមន្ត្រីរាជការ នៃក្រសួងទេសចរណ៍ ចំនួន០៦រូប ដែលមាន ស្នាដៃល្អក្នុងការបំពេញភារកិច្ចលើវិស័យទេសចរណ៍ ដូចមានរាយនាមខាងក្រោម :-

១-លោក **អ៊ុន ធឿន** អគ្គនាយករងទេសចរណ៍ ក្រសួងទេសចរណ៍
២-លោក **គង់ សុលីដា** អគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងទេសចរណ៍
៣-លោក **ម៉ៅ សុមិត្រា** ប្រធាននាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស ក្រសួងទេសចរណ៍
៤-លោក **អ៊ុក សុខា** ប្រធាននាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ ក្រសួងទេសចរណ៍
៥-លោក **សុខ តុងហាប់** ប្រធាននាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ ក្រសួងទេសចរណ៍
៦-លោកស្រី **ឈូក ឈុំខឿ** អនុប្រធាននាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស ក្រសួងទេសចរណ៍

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងទេសចរណ៍ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ១០ ឆ្នាំ ២០០៩
នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និង មាត្រា២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:១៥៤០ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងសាធារណការ និងដឹកជញ្ជូន

## សម្រេច

**មាត្រា១.-**

ត្រូវបានបំពាក់ **មេដាយសហមេត្រី** តាមលំដាប់ថ្នាក់ ចំនួន០៥គ្រឿង ជូនអ្នកជំនាញការ ទីប្រឹក្សាបច្ចេកទេស និងនិយោជិតក្រុមហ៊ុនសាងសង់ ដែលបានខិតខំអស់ពីកម្លាំងកាយចិត្ត ក្នុងកិច្ចសហការជួយជំរុញការងារស្ថាបនាកំណាត់ផ្លូវជាតិ លេខ ៥-៦ (សៀមរាប-ប៉ោយប៉ែត) និង ស្ពាន លូ លើកំណាត់ផ្លូវជាតិ លេខ៥៦ និង លេខ ៦៨ ( ស៊ីសុផុន-សំរោង-ក្រឡាញ់ ) រហូតបញ្ចប់ជាស្ថាពរ ដូចមានរាយនាមខាងក្រោម :-

**ក.-មេដាយសហមេត្រី ថ្នាក់ ធិបឌិន្ទ :**

-លោក SHIHIRU DATE ជំនាញការផ្នែកដឹកជញ្ជូន នៃធនាគារអភិវឌ្ឍន៍អាស៊ី ( Transport Specialist of ADB)

**ខ.-មេដាយសហមេត្រី ថ្នាក់ សេនា :**

១-នាយកដ្ឋានអភិវឌ្ឍន៍ ផ្នែកដឹកជញ្ជូន និង តំបន់ជាយក្រុង នៅអាស៊ីអគ្នេយ៍ នៃធនាគារអភិវឌ្ឍន៍អាស៊ី ( Transport and Urban Development Division Southeast Asia Department of ADB )

២-ក្រុមហ៊ុន ទីប្រឹក្សាបច្ចេកទេស KOREA Consultants International (KCI) និង ជាសមភាគីគំរោង

៣-ក្រុមហ៊ុន ម៉ៅការសាងសង់ SPT CIVIL Group Ltd Partnership

៤-ក្រុមហ៊ុន ម៉ៅការសាងសង់ KC MKK Co., Ltd/ GPCHE, Joint Venture.

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៦៤៧.សសរ

# សេចក្តីសំរេច

## ស្តីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សំ រេ ច

**ប្រការ ១** :ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង** រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជានាយករដ្ឋមន្ត្រីស្តីទី នៃរាជរដ្ឋាភិបាលកម្ពុជា ជំនួសសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវអញ្ជើញទៅបំពេញទស្សនកិច្ចការងារ និងចូលរួមពិធីបើកពិព័ណ៌ពាណិជ្ជកម្ម និងសេដ្ឋកិច្ចអន្តរជាតិភាគខាងលិចប្រទេសចិនលើកទី១០ ចាប់ពីថ្ងៃទី ១៥ ខែតុលា ឆ្នាំ២០០៩ នៅទីក្រុងChengdu ខេត្តស៊ីជាន់ នៃសាធារណរដ្ឋប្រជាមានិតចិន រហូតដល់ពេលសម្តេចតេជោនាយករដ្ឋមន្ត្រី អញ្ជើញវិលនិវត្តន៍មកកាន់មាតុប្រទេសវិញ ។

**ប្រការ ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន អភិបាលរាជធានី អភិបាលគ្រប់ខេត្ត និងឯកឧត្តម ស ខេង ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០០៩*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ២*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ: ៩០២ សហវ.ប្រក.

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៩

# ប្រកាស
## ស្ដីពី
## ការបង្កើត និងដាក់ឲ្យដំណើរការយន្តការតាពជាដៃគូគយ-ផ្នែកឯកជន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៤ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតម្លើងឋានៈនាយកដ្ឋានគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឲ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញសេចក្ដីជូនដំណឹងលេខ ៥០៦ សជណ ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០០៩ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១.-**

បង្កើត និងដាក់ឲ្យដំណើរការយន្តការភាពជាដៃគូគយ-ផ្នែកឯកជន (Customs-Private Sector Partnership Mechanism) ដែលមានសមាសភាពដឹកនាំដូចតទៅ ៖

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម **ប៉ែន ស៊ីម៉ន** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា អគ្គនាយកគយនិងរដ្ឋាករកម្ពុជា | ប្រធាន |
| ២- | លោក **គុណ ញឹម** | អគ្គនាយករងគយនិងរដ្ឋាករកម្ពុជា | អនុប្រធាន |
| ៣- | ប្រធាននាយកដ្ឋានកិច្ចការច្បាប់ សវនកម្ម និងទំនាក់ទំនងសាធារណៈ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | | អនុប្រធានអចិន្ត្រៃយ៍ |
| ៤- | ប្រធាននាយកដ្ឋានផែនការ បច្ចេកទេស និងកិច្ចការអន្តរជាតិ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | | អនុប្រធាន |
| ៥- | ប្រធាននាយកដ្ឋានរបបគយ | | អនុប្រធាន |
| ៦- | តំណាងសភាពាណិជ្ជកម្មកម្ពុជា | | អនុប្រធាន |
| ៧- | តំណាងសមាគមរោងចក្រកាត់ដេរកម្ពុជា | | អនុប្រធាន |
| ៨- | តំណាងសមាគមសហគ្រាសតូច-មធ្យមកម្ពុជា | | សមាជិក |
| ៩- | តំណាងសមាគមដឹកជញ្ជូនកម្ពុជា | | សមាជិក |
| ១០- | លោក **ម៉ូរ ម៉ុនណារ៉ា** | ប្រធានការិយាល័យគយ និងរដ្ឋាករ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | សមាជិក |
| ១១- | លោក **សុខ សុមិទ្ធា** | ជំនួយការលេខាធិការដ្ឋាននៃអគ្គនាយកដ្ឋាន គយ និងរដ្ឋាករកម្ពុជា | លេខាធិការ |
| ១២- | លោក **ឆាំ អេងម៉េង** | អនុប្រធានការិយាល័យត្រួតពិនិត្យ នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | លេខាធិការ |

យន្តការនេះមានលេខាធិការដ្ឋាន នៅទីចាត់ការកណ្តាលនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងមានសិទ្ធិប្រើប្រាស់ត្រារបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ក្នុងការងាររបស់ខ្លួន ។ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ត្រូវចាត់ចែងធានានូវនិរន្តរភាពនៃកិច្ចដំណើរការរបស់លេខាធិការដ្ឋាននៃយន្តការនេះ ។

**ប្រការ ២.-**

យន្តការភាពជាដៃគូគយ-ផ្នែកឯកជន ត្រូវបានបែងចែកជាបីក្រុមការងារជំនាញដូចតទៅ ៖

១- ក្រុមការងារគយ-ឧស្សាហកម្មបម្រើការនាំចេញវិស័យកាត់ដេរ (Customs-Export Oriented Garment Industry Working Group)

២- ក្រុមការងារគយ-ឧស្សាហកម្មបម្រើការនាំចេញវិស័យមិនមែនកាត់ដេរ (Customs-Export Oriented Non-Garment Industry Working Group)

៣- ក្រុមការងារគយ-ធុរកិច្ចបម្រើទីផ្សារក្នុងស្រុក (Customs-Domestic Market Oriented Business Working Group)

**ប្រការ ៣.-**

ក្រុមការងារគយ-ឧស្សាហកម្មបម្រើការនាំចេញវិស័យកាត់ដេរ មានសមាសភាពដូចខាងក្រោម ៖

ក- តំណាងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ៖

- ប្រធាននាយកដ្ឋានកិច្ចការច្បាប់ សវនកម្ម និងទំនាក់ទំនងសាធារណៈ — សហប្រធាន
- ប្រធាននាយកដ្ឋានរបបគយ — អនុប្រធានអចិន្ត្រៃយ៍
- ប្រធានការិយាល័យគយនិងរដ្ឋាករនាំចេញ — សមាជិក
- លោក **ផា អេងម៉េង** អនុប្រធានការិយាល័យត្រួតពិនិត្យ — សមាជិក
- លោក **ប្រាក់ សុម៉េត** អនុប្រធានការិយាល័យគោលនយោបាយនិងគ្រប់គ្រងតំបន់រួចពន្ធ — សមាជិក
- លោក **សុខ សុមិត្រា** ជំនួយការលេខាធិការដ្ឋាន — សមាជិក
- លោក **ម៉ុន ជីម** អនុប្រធានទីស្នាក់ការគយនិងរដ្ឋាករកំពង់ផែក្រុងព្រះសីហនុ — សមាជិក
- លោកស្រី **សឺង សុមណ្ណី** ជំនួយការការិយាល័យគ្រប់គ្រងហានិភ័យនិងសវនកម្ម — សមាជិក

ខ- តំណាងផ្នែកឯកជន ៖

- តំណាងសភាពាណិជ្ជកម្មកម្ពុជា — សហប្រធាន
- តំណាងសមាគមរោងចក្រកាត់ដេរកម្ពុជា — អនុប្រធានអចិន្ត្រៃយ៍
- តំណាងសមាគមដឹកជញ្ជូនកម្ពុជា — សមាជិក
- តំណាងក្រុមហ៊ុន Makalot Garments (Cambodia) Co., Ltd. — សមាជិក
- តំណាងក្រុមហ៊ុន June Textiles Co., Ltd. — សមាជិក
- តំណាងក្រុមហ៊ុន M & V International Manufacturing Ltd. — សមាជិក
- តំណាងក្រុមហ៊ុន Generation International Co., Ltd. — សមាជិក
- តំណាងក្រុមហ៊ុន Suntex PTE Ltd. — សមាជិក
- តំណាងក្រុមហ៊ុន Phnom Penh SEZ Co., Ltd. — សមាជិក

**ប្រការ ៤.-**

ក្រុមការងារគយ-ឧស្សាហកម្មបម្រើការនាំចេញវិស័យមិនមែនកាត់ដេរ មានសមាសភាពដូចខាងក្រោម ៖

ក- តំណាងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ៖

- ប្រធាននាយកដ្ឋានកិច្ចការច្បាប់ សវនកម្ម និងទំនាក់ទំនងសាធារណៈ — សហប្រធាន
- លោក **ម៉ុរ ម៉ុនណារ៉ា** ប្រធានការិយាល័យគយនិងរដ្ឋាករ — អនុប្រធានអចិន្ត្រៃយ៍
- លោក **គឹម ខួន** ប្រធានការិយាល័យគយនិងរដ្ឋាករ — សមាជិក
- លោក **ផា អេងម៉េង** អនុប្រធានការិយាល័យត្រួតពិនិត្យ — សមាជិក
- លោក **ប្រាក់ សុម៉េត** អនុប្រធានការិយាល័យគោលនយោបាយនិងគ្រប់គ្រងតំបន់រួចពន្ធ — សមាជិក

- លោក **អើត សុផ្លាវ៉ា** អនុប្រធានសាខាគយនិងរដ្ឋាករខេត្តព្រះសីហនុ សមាជិក
- លោក **សខ់ សិទ្ធានិត្យ** ជំនួយការការិយាល័យត្រួតពិនិត្យ សមាជិក
- លោក **សាយសេខឡាយ** ជំនួយការការិយាល័យគ្រប់គ្រងហានិភ័យនិងសវនកម្ម សមាជិក

ខ- តំណាងផ្នែកឯកជន ៖

- តំណាងសភាពាណិជ្ជកម្មកម្ពុជា សហប្រធាន
- តំណាងសមាគមសហគ្រាសតូច-មធ្យមកម្ពុជា អនុប្រធាន
- តំណាងសមាគមដឹកជញ្ជូនកម្ពុជា សមាជិក
- តំណាងក្រុមហ៊ុន KTC Cable Co., Ltd. សមាជិក
- តំណាងក្រុមហ៊ុន British American Tobacco Cambodia Co., Ltd. សមាជិក
- តំណាងក្រុមហ៊ុន Mong Rithy Group Co., Ltd. សមាជិក
- តំណាងក្រុមហ៊ុន Cambodia Brewery Limited. សមាជិក
- តំណាងក្រុមហ៊ុន Cambrew Ltd. សមាជិក
- តំណាងក្រុមហ៊ុន Crown Beverage Cans (Cambodia) Limited សមាជិក
- តំណាងក្រុមហ៊ុន C P Cambodia Co., Ltd. សមាជិក
- តំណាងក្រុមហ៊ុន Phnom Penh SEZ Co., Ltd. សមាជិក

**ប្រការ ៥.-**

ក្រុមការងារគយ-ធុរកិច្ចបម្រើទីផ្សារក្នុងស្រុកមានសមាសភាពដូចខាងក្រោម ៖

ក- តំណាងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ៖

- ប្រធាននាយកដ្ឋានកិច្ចការច្បាប់ សវនកម្ម និងទំនាក់ទំនងសាធារណៈ សហប្រធាន
- ប្រធាននាយកដ្ឋានផែនការ បច្ចេកទេស និងកិច្ចការអន្តរជាតិ អនុប្រធានអចិន្ត្រៃយ៍
- លោក **អ៊ុយ កុសល** អនុប្រធាននាយកដ្ឋានកិច្ចការច្បាប់សវនកម្ម និងទំនាក់ទំនងសាធារណៈ អនុប្រធាន
- លោក **ម៉ុរ ម៉ុនណាវ៉ា** ប្រធានការិយាល័យគយនិងរដ្ឋាករ សមាជិក
- លោក **សខ់ ស៊ីណាមិត្ត** ជំនួយការនាយកដ្ឋានផែនការ បច្ចេកទេស និងកិច្ចការអន្តរជាតិ សមាជិក
- លោក **សុខ សុមិត្តា** ជំនួយការលេខាធិការដ្ឋាន សមាជិក
- លោក **រស់ ដាវ៉ា** អនុប្រធានទទួលបន្ទុករួមការិយាល័យគោលនយោបាយគយ សមាជិក
- លោក **ដួង ឫលីន** ជំនួយការលេខាធិការដ្ឋាន សមាជិក
- លោក **ចិន អួន** ជំនួយការលេខាធិការដ្ឋាន សមាជិក

ខ- តំណាងផ្នែកឯកជន ៖

- តំណាងក្រុមហ៊ុន L.Y.P GROUP CO., LTD. សហប្រធាន
- តំណាងក្រុមហ៊ុន Unilever (Cambodia) Limited អនុប្រធាន
- តំណាងក្រុមហ៊ុន Good Will Trading Co., Ltd. សមាជិក

- តំណាងក្រុមហ៊ុន Good Hill Enterprise (Cambodia) Ltd. សមាជិក
- តំណាងក្រុមហ៊ុន Anco Brothers Co., Ltd. សមាជិក
- តំណាងក្រុមហ៊ុន Sok Kong Import Export Co., Ltd. សមាជិក
- តំណាងក្រុមហ៊ុន CHEVRON (Cambodia) Limited សមាជិក
- តំណាងក្រុមហ៊ុន Men Sarun Flour Factory Ltd. សមាជិក

**ប្រការ ៦.-**

យន្តការភាពជាដៃគូគយ-ផ្នែកឯកជន ដូចមានចែងក្នុងប្រការខាងលើមានតួនាទីដូចខាងក្រោម ៖

- សហការស្វែងយល់ទៅវិញទៅមក រវាងរដ្ឋបាលគយ និងផ្នែកឯកជន នូវរាល់សំណូមពរចាំបាច់នានា ដែលភាគីទាំងពីរចង់បាន ក្នុងគោលបំណងលើកស្ទួយសីលធម៌សារពើពន្ធ និងការសម្រួលពាណិជ្ជកម្មឲ្យបានជាអតិបរមា ជាពិសេសតម្រូវការនៃការយល់ដឹងពីបទប្បញ្ញត្តិជាធរមាន ការជម្រុញកម្រិតអនុលោមភាពច្បាប់ និងការធ្វើសាមញ្ញកម្មនីតិវិធីគយ ឈានទៅកាត់បន្ថយការចំណាយ និងការយឺតយ៉ាវនានាក្នុងការបំពេញបែបបទគយ
- សម្របសម្រួលឲ្យមានកិច្ចសហការយោគយល់គ្នាទៅវិញទៅមកល្អ តាមបទប្បញ្ញត្តិជាធរមាន រវាងរដ្ឋបាលគយ និងផ្នែកឯកជនពាក់ព័ន្ធ និងចូលរួមដោះស្រាយនូវរាល់បាតុភាពអសកម្ម និងភាពមិនយល់គ្នានានា ដើម្បីអនុវត្តគោលនយោបាយនៃកិច្ចសម្រួលពាណិជ្ជកម្មរបស់រាជរដ្ឋាភិបាលឲ្យមានប្រសិទ្ធភាព
- សម្របសម្រួលឲ្យមានការចូលរួមរបស់ផ្នែកឯកជនពាក់ព័ន្ធ ក្នុងដំណើរការកសាង និងកែសម្រួលបទប្បញ្ញត្តិនានា ជាពិសេសតារាងតម្លៃចម្លងការនៃទំនិញ ឲ្យមានអនុលោមភាពទៅតាមបញ្ញត្តិប្រកាសលេខ ៣៨៧ សហវ.ប្រក ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៨ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការកំណត់តម្លៃគិតពន្ធគយលើទំនិញនាំចូល ។

**ប្រការ ៧.-**

យន្តការភាពជាដៃគូគយ-ផ្នែកឯកជន ដូចមានចែងខាងលើមានសិទ្ធិ និងការកិច្ចដូចខាងក្រោម ៖

- រៀបចំឲ្យមានកិច្ចប្រជុំ រៀងរាល់ដំណាច់ត្រីមាសនីមួយៗ ដើម្បីរួមគ្នាសម្របសម្រួលដោះស្រាយរាល់បញ្ហាមិនប្រក្រតីនានា ដែលត្រូវបានលើកឡើងដោយភាគីពាក់ព័ន្ធនៃបញ្ហានេះ ។ ក្នុងករណីយល់ថាចាំបាច់ ឬបន្ទាន់មិនអាចរង់ចាំបាន ប្រធានយន្តការភាពជាដៃគូគយ-ផ្នែកឯកជនអាចកោះប្រជុំវិសាមញ្ញនៅពេលណាមួយក៏បាន ។ យន្តការនេះមានសិទ្ធិអញ្ជើញតំណាងស្ថាប័នមានសមត្ថកិច្ច និងតំណាងផ្នែកឯកជនពាក់ព័ន្ធ ដើម្បីចូលរួមពិភាក្សាក្នុងកិច្ចប្រជុំនេះ
- ភាគីពាក់ព័ន្ធ ដូចមានចែងក្នុងបញ្ញត្តិប្រការ ៣ ប្រការ ៤ និងប្រការ ៥ នៃប្រកាសនេះ ដែលពុំមានបញ្ជាក់នាមជារូបវន្តបុគ្គលនោះ អាចចាត់តាំងតំណាងផ្លូវការរបស់ខ្លួនឲ្យមកចូលរួមប្រជុំ ដែលអាចផ្លាស់ប្តូរបានពីពេលមួយទៅពេលមួយ
- ផ្អែកតាមលទ្ធផលនៃកិច្ចពិភាក្សាសម្របសម្រួល និងក្នុងករណីតម្រូវឲ្យមានការសម្រេចដោយឡែកពីស្ថាប័នមានសមត្ថកិច្ចលើការកែសម្រួល បំពេញបន្ថែម ឬ/និង ចេញសេចក្តីសម្រេច

ណាមួយបន្ថែមទៀតនោះ យន្តការនេះត្រូវចាត់ចែងរៀបចំឯកសារពាក់ព័ន្ធ ដាក់ជូនស្ថាប័នមានសមត្ថកិច្ចដើម្បីពិនិត្យ និងសម្រេច

- ត្រូវធ្វើរបាយការណ៍ស្តីពីលទ្ធផលនៃរាល់កិច្ចប្រជុំ និងស្តីពីសកម្មភាពការងាររបស់ខ្លួនឲ្យបានទៀងទាត់ ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ប្រការ ៨.-**

មន្ត្រីរាជការគយនិងរដ្ឋាករដូចមានចែងក្នុងប្រការនានាខាងលើនៃប្រកាសនេះ ត្រូវបំពេញការកិច្ចតាមបញ្ញត្តិនៃប្រកាសនេះបន្ថែមលើមុខងារបច្ចុប្បន្ន ។

តាមសំណើរបស់ផ្នែកឯកជនពាក់ព័ន្ធ និងក្នុងករណីចាំបាច់ ប្រធានយន្តការភាពជាដៃគូគយ-ផ្នែកឯកជនអាចកែសម្រួល ឬបំពេញបន្ថែមសមាសភាពនៃក្រុមការងារជំនាញនីមួយៗនៃយន្តការនេះ ។

ការកែសម្រួល ឬបំពេញបន្ថែមសមាសភាពដឹកនាំយន្តការភាពជាដៃគូគយ-ផ្នែកឯកជន ដូចចែងក្នុងប្រការ ១ ខាងលើ ត្រូវកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ប្រការ ៩.-**

បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ១០.-**

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកគយនិងរដ្ឋាករកម្ពុជា អគ្គលេខាធិការ អគ្គនាយក នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពនានានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងបុគ្គលពាក់ព័ន្ធទាំងអស់ ត្រូវអនុវត្តតាមប្រកាសនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- គណៈកម្មាធិការដឹកនាំការងារដើម្បីអភិវឌ្ឍន៍ផ្នែកឯកជន
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- គ្រប់សាលាខេត្ត-ក្រុងដែលពាក់ព័ន្ធ
- សភាពាណិជ្ជកម្មកម្ពុជា

"ដើម្បីជូនជ្រាប"

- ដូចប្រការ ១០ "ដើម្បីអនុវត្ត"
- ឯកសារ - កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ៩០៧ សហវ.ប្រក.

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៩

# ប្រកាស

## ស្តីពី

## ការកំណត់តម្លៃឆ្លងកាត់ លើមុខទំនិញមួយចំនួនដែលស្ថិតក្រោមនីតិវិធីឆ្លងកាត់គយ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឲ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
